# **សម្តេចក្រឡាហោម ស ខេង៖** ក្រសួងពាក់ព័ន្ធ សមត្ថកិច្ច និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ចាំបាច់ត្រូវរិះរកនីតិវិធីក្នុងការកែលម្អស្ថានភាពនេះជាបន្ទាន់ រួមទាំងការដោះស្រាយបញ្ហាប្រជាពលរដ្ឋដែលកំពុងមានតម្រូវការមូលដ្ឋាន

នៅក្នុងឱកាស នៃការប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៦ ដែលប្រព្រឹត្តទៅនៅសាលមហោស្រព និងពិព័រណ៌កោះពេជ្រ នាថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ** ព្រមទាំងមានការនិមន្តព្រះសង្ឃ និងមានការចូលរួមរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ អន្តរជាតិ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត តាជី យាយជី ប្រជាពលរដ្ឋ។




**សម្តេចក្រឡាហោម ស ខេង** មានប្រសាសន៍ទាក់ទងទៅនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបង្ការ ទប់ស្កាត់ រាល់បទល្មើសដែលមានខ្លឹមសារដូចខាងក្រោមថា៖ រាជរដ្ឋាភិបាលក៏ដូចជាដៃគូពាក់ព័ន្ធ បានខិតខំ បង្ការទប់ស្កាត់ តាមរយៈការអប់រំ ផ្សព្វផ្សាយ គ្រប់រូបភាព គ្រប់ទីកន្លែង តាមគ្រប់មធ្យោបាយ តែទន្ទឹមនឹងនោះក៏មានការផ្សព្វផ្សាយដោយបណ្តាញក្រុមទុច្ចរិតមួយចំនួន ដែលនៅតែអាចបោកប្រាស់ប្រជាពលរដ្ឋឲ្យលង់ខ្លួន ខាតបង់លុយកាក់ និងធ្លាក់ខ្លួនរងគ្រោះបាន។ដូច្នេះក្នុងការបង្ការទប់ស្កាត់ ទាមទារឲ្យមានការបង្កើតជាជម្រើសសម្រាប់ការរស់នៅរបស់គ្រួសារ បន្ថែមទៀត និងតាមដានសកម្មភាពក្រុមហ៊ុនទុច្ចរិតមួយចំនួន ដែលមិនមានការទទួលខុសត្រូវ ឲ្យប្រឈមមុខជាមួយច្បាប់។




ទីភ្នាក់ងារមុខរបរ និងការងាររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏បានស្វែងរកកិច្ចសហការជាមួយបណ្តារោងចក្រ សហគ្រាស និងម្ចាស់អាជីវកម្មទាំងឡាយ ដើម្បីផ្តល់ព័ត៌មានអំពីទីផ្សារការងារ និងមុខរបរសមស្របជូនដល់ប្រជាពលរដ្ឋដែលមានតម្រូវការ។ យើងបានបើកទូលាយឲ្យមានកិច្ចសហការ ជាមួយដៃគូអភិវឌ្ឍន៍ និងផ្នែកឯកជននានា ដើម្បីឲ្យប្រជាពលរដ្ឋយើង ជាពិសេសយុវជន ស្ត្រី និងកុមារទទួលបានព័ត៌មាន ចំណេះដឹងបច្ចេកទេស និងជំនាញបំណិនជីវិត ដើម្បីអាចការពារខ្លួនពីកលល្បិចជនល្មើស ដែលតែងតែព្យាយាមអូសទាញឲ្យធ្លាក់ចូលក្នុងការកេងប្រវ័ញ្ច អំពើជួញដូរមនុស្ស និងការប្រព្រឹត្តបទល្មើសផ្សេងៗ។ ចំពោះជនរងគ្រោះ រាជរដ្ឋាភិបាល បានសហការជាមួយអង្គការដៃគូមួយចំនួនដែលមានទិសដៅរួមគ្នា ជួយផ្តល់កិច្ចការពារ និងសេវាសមស្របនានា ដើម្បីធានាសុវត្ថិភាព និងការពារមិនឲ្យទទួលរងភាពរងគ្រោះជាថ្មី ។



**សម្តេចក្រឡាហោម** មានប្រសាសន៍បញ្ជាក់បន្ថែមទៅដល់ ក្រសួងពាក់ព័ន្ធ សមត្ថកិច្ច និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ថា “ចាំបាច់នូវវិះរកនីតិវិធីក្នុងការកែលម្អស្ថានភាពនេះជាបន្ទាន់ រួមទាំងការដោះស្រាយបញ្ហាប្រជាពលរដ្ឋដែលកំពុងមានតម្រូវការមូលដ្ឋាន” ដើម្បីសម្រួលដល់ការរស់នៅ និងមានឱកាសបង្កើតការងារមុខរបរល្អៗនៅក្នុងស្រុក ជិតផ្ទះសម្បែង បានថែទាំកូនចៅ ដីស្រែចម្ការ ច្បារដំណាំ និងបង្កើនចំណូលជាប្រចាំ មិនចាំបាច់រងគ្រោះ និងរងការប្រមាថមើលងាយដូចសព្វថ្ងៃនេះឡើយ ។ មិនតែប៉ុណ្ណោះ ក្រសួង ស្ថាប័ន និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ គប្បីតាមដានត្រួតពិនិត្យ ដោយយកចិត្តទុកដាក់ ដោះស្រាយបញ្ហាដែលកើតមានតាមមុខសញ្ញា នៃការទទួលខុសត្រូវរបស់ខ្លួនឲ្យបានល្អ និងជម្រុញការផ្តល់សេវាចាំបាច់ឲ្យដល់ដៃប្រជាពលរដ្ឋទាន់ពេល តាមតម្រូវការ ជៀសវាងការទុកឲ្យបញ្ហាកាន់តែស្មុគ្រស្មាញ ដែលអាចជម្រុញឲ្យប្រជាពលរដ្ឋប្រឈមនឹងហានិភ័យដោយចំណាកស្រុក និងអំពើជួញដូរមនុស្ស ។ បង្កើនការយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងលំហូរចេញចូល នៃជនទេសន្តរប្រវេសន៍ តាំងពីក្នុងមូលដ្ឋានរហូតដល់តាមខ្សែបន្ទាត់ព្រំដែន ទាំងដែនទឹក ដែនគោក និងដែនអាកាស ព្រមទាំងតាមដានឃ្លាំមើលសកម្មភាពគួរឲ្យសង្ស័យរបស់ជនល្មើស ដើម្បីបង្ការ និងបង្ក្រាបឲ្យទាន់ពេលវេលា ។












